# ស្ថានទូតអូស្ត្រាលី

## ភ្នំពេញ

៥៥⑩៧៧

# សេចក្តីប្រកាសពត៌មាន

៥៥⑩៧៧

## អូស្ត្រាលីបំពេញក្របខ័ណ្ឌការងារគ្រប់គ្រងបេតិកភ័ណ្ឌជាមួយកម្ពុជា

ថ្ងៃនេះ ប្រទេសអូស្ត្រាលីបានចុះអនុស្សារណៈនៃការយោគយល់គ្នាមួយជាមួយអង្គការ UNESCO និង អាជ្ញាធរអប្សារា (APSARA) នៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីចាប់ផ្តើមអនុវត្តគំរោងក្របខ័ណ្ឌការងារគ្រប់គ្រងបេតិកភ័ណ្ឌអង្គរវត្ត ។

ប្រទេសអូស្ត្រាលី បានផ្តល់ទឹកប្រាក់ចំនួន ១.១៣ លានដុល្លាអូស្ត្រាលី ដើម្បីជួយដល់ការអនុវត្តន៍ផែនការនេះ ។ ប្រទេសអូស្ត្រាលីសូមស្វាគមន៏ផងដែរចំពោះវិភាគកទានជាទឹកប្រាក់ចំនួន ៦00,000 ដុល្លាសហរដ្ឋអាមេរិក របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីជួយដល់គំរោងនេះ ។

លោកជំទាវ Margaret Adamson ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា បានមានប្រសាសន៏ថា គំរោងក្របខ័ណ្ឌការងារគ្រប់គ្រងបេតិកភ័ណ្ឌនេះ នឹងជួយដល់ការអភិរក្សបេតិកភ័ណ្ឌអង្គរវត្តដ៏មានតំលៃជាសាកល ដើម្បីធ្វើអោយមានភាពប្រសើរឡើងលើការងារអភិបាលកិច្ច និងជួយកាត់បន្ថយភាពក្រីក្រនៅទីជនបទ ។

គំរោងក្របខ័ណ្ឌការងារគ្រប់គ្រងបេតិកភ័ណ្ឌ នឹងចូលរួមចំណែកបន្ថែមទៀតលើការអភិវឌ្ឍន៏ប្រកបដោយចេរភាព និងកាត់បន្ថយភាពក្រីក្រនៅខេត្តសៀមរាប ដែលជាខេត្តមួយក្នុងចំណោមខេត្តក្រីក្របំផុតនៅក្នុងប្រទេសកម្ពុជា តាមរយៈការជួយដល់សហគមន៏មូលដ្ឋានអោយទទួលបានការចែករំលែកផលប្រយោជន៏សេដ្ឋកិច្ច និង វប្បធម៌ ដែលបានមកពីវិស័យទេសចរណ៏នៅអង្គរវត្ត ។

មេរៀនដែលបានរៀនមកពីក្របខ័ណ្ឌការងារគ្រប់គ្រងបេតិកភ័ណ្ឌ លើការគ្រប់គ្រងតំបន់វប្បធម៌ សហគមន៏មូលដ្ឋាន និងការរីកលូតលាស់ឡើងនៃវិស័យទេសចរណ៏ នឹងផ្តល់ផលប្រយោជន៏ដល់តំបន់បេតិកភ័ណ្ឌដ៏ទៃទៀតនៅពេលអនាគត នៅក្នុងប្រទេសកម្ពុជា និងនៅលើសាកលលោក ។

No 16B, National Assembly Street, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

គំរោងក្របខ័ណ្ឌការងារគ្រប់គ្រងបេតិកភ័ណ្ឌនេះ បានបង្ហាញនូវកិច្ចសហប្រតិបត្តិការប្រកបដោយជោគជ័យអស់រយៈពេលជាច្រើនឆ្នាំកន្លងមករវាងអ្នកជំនាញជាច្រើនដែលមកពីអជ្ញាធរអប្សរា អង្គការ UNESCO និងសាកលវិទ្យាល័យស៊ីដនី (University of Sydney) ។ អង្គការទាំងនេះបានធ្វើការស្រាវជ្រាវរួមគ្នាលើការគ្រប់គ្រង និងអភិបាលកិច្ចដើម្បីបង្កើតនូវទំរង់ថ្មីមួយនៃប្រព័ន្ធត្រួតពិនិត្យបេតិកភ័ណ្ឌដោយផ្អែកលើតំលៃសហគមន៏ គោលការណ៍ជាតិ និងការអនុវត្តល្អបំផុតលីការងារបេតិកភ័ណ្ឌអន្តរជាតិ ។

ភាពជាដៃគូរដ៏យូរអង្វែងនេះ នឹងត្រូវបានទទួលស្គាល់បង្ហាញអោយឃើញនៅក្នុងពិធីអាហារពេលល្ងាចមួយ ដែលរៀបចំឡើងដោយសាកលវិទ្យាល័យស៊ីដនី និងស្ថានទូតអូស្ត្រាលី នៅប្រាសាទបាយ័ននៅថ្ងៃទី១៥ ខែធ្នូ ២០០៩ ខាងមុខនេះ ។

ទិសដៅបង្កើតថ្មី នៃការអភិរក្សបេតិកភ័ណ្ឌដ៏មានប្រសិទ្ធភាពរបស់អូស្ត្រាលី ត្រូវបានយកជាគំរូតាមដោយប្រទេសដទៃទៀត ក្រោមការជួយជ្រោមជ្រែងពីអ្នកជំនាញអូស្ត្រាលី ។ ធម្មនុញ្ញ ប៊ូរ៉ាឆាតធើ (The Burra Charter) ដែលបញ្ជាក់ពីចំណុចសំខាន់របស់ក្រុបប្រឹក្សាអភិរក្សវិមាន និងតំបន់បេតិកភ័ណ្ឌ ទស្សនះវិទ្យា និងវិធីសាស្ត្រវិទ្យា អន្តរជាតិរបស់ប្រទេសអូស្ត្រាលី (ICOMOS) ត្រូវបានទទួលស្គាល់ជាអន្តរជាតិថាជាការអនុវត្តដ៏ល្អបំផុតនៅលើពិភពលោក ។


**ទំនាក់ទំនងសារព័តមាន:**

*លោកស្រី **ហ្វីយ៉ូណា ខូឆូ** **(Ms Fiona Cochaud), DHOM, 023 213 470***

**ស្ថានទូតអូស្ត្រាលី រាជធានីភ្នំពេញ**


ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៩